ជំពូកទី៣ : ការអធិប្បាយគំរោង

៣.១ សាវតាក្រុមហ៊ុន

៣១. ក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. ជាក្រុមហ៊ុនសាជីវកម្មខ្មែរបរទេស (កម្ពុជា-ចិន) បានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ជាមួយនឹងការដាក់ដើមទុនវិនិយោគដំបូងចំនួន ៥០០ ,000,000រៀល នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០។ ក្រុមហ៊ុននេះបានទទួលអាជ្ញាប័ណ្ណស្វែងរុករករ៉ែពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីធ្វើការស្រាវជ្រាវលើរ៉ែមាស ក្រោមលិខិតលេខ ៩៦៩ ឧរថ.ធរ.អប ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩ លើផ្ទៃដីសរុបចំនួន១០០ហិកតា។ ក្រុមហ៊ុនគ្រោងវិនិយោគទឹកប្រាក់បន្ថែមចំនួន ២.៤៥ លានដុល្លា ដើម្បីរៀបចំប្រព័ន្ធផលិតកម្មមាស និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការសាងសង់ផ្លូវផ្សេងៗ។

៣២. ក្រុមហ៊ុននេះ លោក **ញ៉ែម ថាវី** ជាអភិបាលក្រុមហ៊ុន មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ ៧ ផ្លូវលេខ ៥៦៤ ក្រុមទី ៤៤ ភូមិ៧ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១៦ ៨១៤ ៧៣១ និងអ៊ីមែល: tvnhem@yahoo.com ។

៣.២ ស្ថានភាពលិខិតបទដ្ឋាន

ឯកសារគោលការណ៍ច្បាប់ដែលក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. បានទទួលពីរាជរដ្ឋាភិបាលកម្ពុជា មានដូចខាងក្រោម:

ក- អាជ្ញាប័ណ្ណស្វែងរករ៉ែ លេខ ៩៦៩ ឧរថ.ធរ.អប ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអនុញ្ញាតអោយក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. ធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែមាស នៅតំបន់ភ្នំដែក។

ខ- លិខិតលេខ ១៩០ សជណ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជំរាបជូនឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ករណីសំណើវិនិយោគសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ នៅស្រុកត្រវែង ខេត្តព្រះវិហារ។

គ- កិច្ចព្រមព្រៀង ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ១៩៩៤ ស្តីពីវិនិយោគទុនរ៉ែ នៅតំបន់ភ្នំដែក ស្រុកត្រវែង ខេត្តព្រះវិហារ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងឧស្សាហកម្ម រ៉ែ និង

ថាមពល និង ក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. ដែលជាក្រុមហ៊ុនមួយ ត្រូវបានបង្កើតឡើងស្របតាមច្បាប់របស់ប្រទេសកម្ពុជា (ឧបសម្ព័ន្ធ៣-១)។

៣៣. ដីសម្បទានដែលក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. សិក្សាស្រាវជ្រាវមានទំហំ ១០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រតំបន់ភ្នំដែក ឃុំរមៀទម ស្រុកវៀង ខេត្តព្រះវិហារ ដែលមានទីតាំងនិយាមកាដូចខាងក្រោម :

ចំណុច	អាប់ស៊ីស	អរដោណេ
A	X = 489839	Y = 1479000
B	X = 493839	Y = 1479000
C	X = 493839	Y = 1478750
D	X = 489839	Y = 1478750

៣៤. ដីសម្បទាននេះអាចចូលតាមផ្លូវពីភូមិត្រពាំងទន្ទឹមជាចំណុចបំបែកចេញពីផ្លូវជាតិលេខ ៦២ មានចំងាយ ១០ គីឡូម៉ែត្រ ឆ្ពោះទៅកាន់ក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. តាមផ្លូវលំទៅកាន់ភូមិរំដេង (ជាឧបសម្ព័ន្ធភូមិត្រពាំងទន្ទឹម) ហើយមានស្ថានភាពផ្លូវលំបាកខ្លះៗក្នុងការធ្វើដំណើរ។ ដីនេះមានព្រំប្រទល់ខាងជើងស្ថិតចន្លោះចំណុចនិយាមកា ៤៨៩៨៣៩-១៤៧៩០០០ និង ៤៩៣៨៣៩-១៤៧៩០០០ ព្រំប្រទល់ខាងកើតស្ថិតត្រង់ចន្លោះចំណុចនិយាមកា ៤៩៣៨៣៩-១៤៧៩០០០ និង ៤៩៣៨៣៩-១៤៧៨៧៥០ ព្រំប្រទល់ខាងត្បូងស្ថិតត្រង់ចន្លោះចំណុចនិយាមកា ៤៩៣៨៣៩-១៤៧៨៧៥០។ ចំណែកឯព្រំប្រទល់ខាងលិចស្ថិតត្រង់ចន្លោះចំណុចនិយាមកា ៤៨៩៨៣៩-១៤៧៩០០០ និង ៤៨៩៨៣៩-១៤៧៨៧៥០។

៣៥. ក្រុមហ៊ុនបានធ្វើការស្រាវជ្រាវអំពីសន្និធិរបស់រ៉ែចាប់ពីឆ្នាំ ២០០២ ដល់ខែសីហា ឆ្នាំ ២០០៥ និងពីខែតុលា ឆ្នាំ ២០០៩ រហូតមកទល់នឹងបច្ចុប្បន្ន ដោយមានការចូលរួមពីវិទ្វូ និងអ្នកបច្ចេកទេសខ្លួងរ៉ែមកពីប្រទេសចិន។ ក្រុមហ៊ុនបានដាក់របាយការណ៍ស្តីពីការស្រាវជ្រាវនេះអោយទៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដើម្បីពិនិត្យ។

៣.៣ លទ្ធផលនៃការស្រាវជ្រាវ និងរុករក

៣៦. ការសិក្សាអំពីសន្និធិរ៉ែមាស នៅក្នុងតំបន់សម្បទានរ៉ែនេះបង្ហាញថា មានរ៉ែមាសសរុបចំនួន ៤០០,០០០តោន ស្ថិតក្នុងកំរិតកំហាប់មាសក្នុងរ៉ែមាស០១តោន ជាមធ្យមមានចំនួយ១.៨៥ម.ក្រ។ ដូច្នេះ នៅទូទាំងតំបន់សម្បទាន មានមាសសុទ្ធសរុបប្រមាណ ៧៤០ត.ក្រ។

៣.៤ ប្រតិបត្តិការប្រព័ន្ធប្រព្រឹត្តកម្មសំណល់រឹងនិងភាវរបស់ក្រុមហ៊ុន DELCOM

៣.៤.១ វិធីជីក និងបំបែកថ្ម

១០៩. នៅតាមទីតាំងនៃអណ្តូងរ៉ែនីមួយៗ ដើម្បីបំបែកយកថ្មជាដុំតូចៗ ក្នុងមួយលើកៗ ត្រូវប្រើ:

- ម៉ូទ័រខួងថ្ម (ប្រើកំលាំងខ្យល់) ផ្នែខួងមានមុខកាត់៣២ម.ម។ ខួងជារុន្ធ និងជាជួរៗ មានចំនួនប្រមាណពី ១០-២០រុន្ធ (តាមស្ថានភាពជាក់ស្តែង) ដែលរុន្ធនីមួយៗ មានជំរៅពី ១.៥-២.០ម៉ែត្រ។
- បន្តមកតាមរុន្ធនីមួយៗ ត្រូវច្រកគ្រឿងផ្ទុះ (អាម៉ូនីញ៉ូនីត្រាត - $NH_3(NO_3)$) ជាមធ្យម០១គីឡូក្រាម, T.A.N Emulsion Explosive ∅៣២ ចំនួន0.៥0គីឡូក្រាម និងដាក់គីបសំរាប់បំផ្ទុះមួយគ្រាប់។ ហើយបន្តខ្សែអគ្គីសនីចេញពីគីបនេះមកខាងលើមាត់អណ្តូង និងភ្ជាប់ចរន្តអគ្គីសនីដើម្បីចុចបំផ្ទុះបំបែកថ្ម។

៣.៤.២ ការដឹកជញ្ជូន និងកិនបំបែក

១១០. បន្ទាប់ពីការបំបែកថ្មនៅក្នុងអណ្តូង យើងដឹកជញ្ជូនថ្មនេះមកខាងលើដោយ:

- កាយយកថ្មដែលបានបំបែករួចដាក់ក្នុងធុងដែកចំណុះ២០០លីត្រ យោងឡើងមកខាងលើត្រង់មាត់អណ្តូង ហើយដាក់ធុងមានថ្មនេះនៅលើរទេះរុញ (កង់ដែក៤) នឹងរុញតាមផ្លូវដែកឆ្ពោះទៅកន្លែងចាក់ថ្ម។ ថ្មមួយផ្នែកធំដែលគ្មានរ៉ែ (Non-Acid Generated Rocks) ត្រូវបានរុញទៅចាក់ជាគំនរទុកចោលនៅលើដី នឹងថ្មមួយផ្នែកដែលមានរ៉ែ (Sulfure Contained and/or Acid-Generated Rocks) គឺ ត្រូវបានយកមកកិនបំបែកអោយម៉ត់ ដោយប្រើម៉ាស៊ីនម៉ាស៊ូតកំលាំង១៨សេះ ទាញត្បាល់បំបែកថ្ម។
- ដើម្បីកិន រែង និងទាញយករ៉ែ យើងប្រើប្រាស់ទឹកដែលបានបូមចេញពីអណ្តូង មកស្តុកទុកក្នុងអាងទឹក (អាងរៀបឥដ្ឋចាក់ស៊ីម៉ង់ត៍) ហើយបង្ហូរចេញមកប្រើប្រាស់។ ទឹករួចពីការប្រើប្រាស់រួចមានកករកំទិចដី-ថ្ម បានហូរចូលក្នុងស្រះទី-១។ ក្នុងស្រះនេះ ទឹកកករកំទិចដី-ថ្ម បានរងធ្លាក់ទៅបាតក្រោម នៅពេលមានបរិមាណច្រើនទើបកាយយកចេញពីក្នុងស្រះមកដាក់លើដីតាមមាត់ស្រះដែលមានទំនប់ព័ទ្ធជុំវិញ។ ចំពោះទឹកក្នុងស្រះទី-១ បានបន្តហូរចូលទៅក្នុងស្រះទី-២ ដែលជាស្រះសម្រាប់ស្តុកទឹកទុក ដើម្បីបូមយកមកប្រើប្រាស់ឡើងវិញ។

៣.៤.៣ ការគ្រប់គ្រងសំណល់

១១១. ក្រោយការកិនបំបែកថ្ម និងកាយយកកករកំទិចថ្មក្នុងស្រះទី១ គឺជាកាកសំណល់ដែលក្រុមហ៊ុន បានត្រៀមបំរុងទីតាំងដីទំហំប្រមាណ២០ហិកតា ស្ថិតនៅចំងាយ ១០០ម៉ែត្រពីអណ្តូងរ៉ែ សំរាប់ជីកជាស្រះកប់កាកសំណល់នេះ។ ស្រះនិមួយៗ ជីកមានបណ្តោយ ២៥ម៉ែត្រ ទទឹង២៥ម៉ែត្រ និងជំរៅ០៣ ម៉ែត្រ ។

១១២. ស្រះនិមួយៗ ត្រូវចាក់កំទិចថ្មកាកសំណល់ជាស្រទាប់ៗ ដែល០១ស្រទាបមានកំរាស់ 0.២៥ម៉ែត្រ (ចំណុះ ២៥ម x ២៥ម x 0.២៥ម) និងប្រើកំបោរសទំងន់៣២0គីឡូក្រាម ដើម្បីបាចត្របជិតពីលើសំណល់

Draft